**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ...០២៤/១៤...**ក.ប**/ល.ទ.ច

**សារាចរ**

**ស្តីពី**

**នីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ទៅធ្វើការដោយស្របច្បាប់**

**នៅព្រះរាជាណាចក្រថៃឡង់ដ៍**

កន្លងមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសង្កេតឃើញថា ពលករ ពលការិនីខ្មែរដែលមានបំណងចេញទៅធ្វើការដោយស្របច្បាប់នៅព្រះរាជាណាចក្រថៃឡង់ដ៍ នៅពុំទាន់បានយល់ច្បាស់អំពីនីតិវិធី និងបែបបទនៃការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់នៅឡើយ។

ដើម្បីបង្កើនការយល់ដឹងដល់សាធារណជន និងប្រសិទ្ធភាពក្នុងការជួយដល់ពលករ ពលការិនីខ្មែរដែលមានបំណងទៅធ្វើការដោយស្របច្បាប់នៅព្រះរាជាណាចក្រថៃឡង់ដ៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជូនដំណឹង និងធ្វើការណែនាំដូចខាងក្រោម៖

## ក. អំពីទីកន្លែងចុះឈ្មោះទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍

ពលករ ពលការិនីខ្មែរ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ហើយមានបំណងទៅធ្វើការដោយស្របច្បាប់នៅព្រះរាជាណាចក្រថៃឡង់ដ៍ត្រូវធ្វើការទំនាក់ទំនងចុះឈ្មោះ និងរៀបចំបែបបទនៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការតាមទីកន្លែងដូចខាងក្រោម៖

១. នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬច្រកចេញចូលតែមួយ ឬក្រុមការងារចល័តស្របតាមគោលដៅសាខាផ្តល់លិខិតឆ្លងដែនរបស់ក្រសួងមហាផ្ទៃ ដែលរួមមាននៅខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ កោះកុង ប៉ៃលិន សៀមរាប កំពង់ធំ កំពង់ចាម ស្វាយរៀង ព្រៃវែង និងតាកែវ។

## ខ. អំពីការបញ្ជាក់ភាពជាពលករស្របច្បាប់សម្រាប់ធ្វើលិខិតឆ្លងដែន

មានវិធី ៣យ៉ាង ដើម្បីទទួលបានការបញ្ជាក់ភាពជាពលករស្របច្បាប់ ទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍៖

១. ចំពោះពលករ ពលការិនីដែលមានបំណងទៅធ្វើការតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន (ក្រុមហ៊ុនជ្រើសរើសពលករ) ដែលបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវ៖

- មានកិច្ចសន្យាការងារជាមួយក្រុមហ៊ុន រោងចក្រ សហគ្រាស ឬនិយោជកនៅព្រះរាជាណាចក្រថៃឡង់ដ៍ តាមរយៈក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់ដែលបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បំពេញពាក្យស្នើសុំទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានភ្ជាប់រូបថតទំហំ ៤x៦ ចំនួន ៣សន្លឹក
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (Overseas Cambodian Worker Card) ដែលមានហត្ថលេខាអគ្គនាយកការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២. ចំពោះពលករ ពលការិនីដែលមានបំណងទៅធ្វើការដោយខ្លួនឯង តាមរយៈអគ្គនាយកដ្ឋានការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវៈ

- មានឯកសាររបស់អាជ្ញាធរថៃដែលបញ្ជាក់ថាមានការងារស្របច្បាប់នៅថៃ
- បំពេញពាក្យស្នើសុំទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានភ្ជាប់រូបថតទំហំ ៤x៦ ចំនួន ៣សន្លឹក
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (Overseas Cambodian Worker Card) ដែលមានហត្ថលេខាអគ្គនាយកការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣. ចំពោះពលករ ពលការិនី ដែលបាននឹងកំពុងធ្វើការនៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៍ ហើយមិនទាន់មានឯកសារគ្រប់គ្រាន់តាមច្បាប់ត្រូវៈ
- ទៅបំពេញបែបបទនៅការិយាល័យ "ច្រកចេញ-ចូលតែមួយ" តាមទីកន្លែងដូចខាងក្រោមៈ
  - ការិយាល័យ "ច្រកចេញ-ចូលតែមួយ" ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
  - ការិយាល័យ "ច្រកចេញ-ចូលតែមួយ" ច្រកព្រំ ខេត្តប៉ៃលិន
  - ការិយាល័យ "ច្រកចេញ-ចូលតែមួយ" ច្រកចាំយាម ខេត្តកោះកុង
  - ការិយាល័យ "ច្រកចេញ-ចូលតែមួយ" ច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ។

- មានឯកសាររបស់អាជ្ញាធរថៃដែលបញ្ជាក់ថាមានការងារស្របច្បាប់នៅថៃ
- បំពេញពាក្យស្នើសុំទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានភ្ជាប់រូបថតទំហំ ៤x៦ ចំនួន ៣សន្លឹក
- មានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (Overseas Cambodian Worker Card) ដែលមានហត្ថលេខាអគ្គនាយកការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

បន្ទាប់ពីពលករ ពលការិនីបានបំពេញបែបបទខាងលើ មន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ត្រីនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈប្រចាំច្រកចេញចូលតែមួយ នឹងរៀបចំបញ្ជីឈ្មោះស្នើសុំធ្វើលិខិតឆ្លងដែនធម្មតាដោយអាករជាបន្ទុករបស់រដ្ឋទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត ឬប្រចាំច្រកនៃក្រសួងមហាផ្ទៃ។

## គ. អំពីការធ្វើលិខិតឆ្លងដែន

បន្ទាប់ពីមានការបញ្ជាក់ភាពជាពលករស្របច្បាប់ ពលករ ពលការិនីត្រូវទៅបំពេញសំណុំបែបបទសុំផ្តល់លិខិតឆ្លងដែនធម្មតាដោយផ្ទាល់ខ្លួន នៅនាយកដ្ឋានលិខិតឆ្លងដែននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬនៅសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត ឬប្រចាំច្រកចេញចូលតែមួយដូចជា បំពេញពាក្យស្នើសុំលិខិតឆ្លងដែន ថតរូប ផ្តិតខ្មៅម្រាមដៃ ចុះហត្ថលេខា វាស់កម្ពស់ និងយកគិនភាគស្លាកស្នាម។

**ឃ. អំពីការធ្វើទិដ្ឋាការការងារ**

បន្ទាប់ពីពលករ ពលការិនីទទួលបានលិខិតឆ្លងដែននោះ ទីភ្នាក់ងារជ្រើសរើសឯកជន (ក្រុមហ៊ុនជ្រើសរើសពលករ) ឬពលករ ពលការិនី ត្រូវយកលិខិតឆ្លងដែនមកនាយកដ្ឋានមុខរបរ និងហាត្ថពលកម្មនៃអគ្គនាយកដ្ឋានការងារ ឬមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំបញ្ជីឈ្មោះជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចុះហត្ថលេខា ផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំទិដ្ឋាការការងារ និងផ្ញើទៅក្រសួងការងារថៃ ដើម្បីស្នើសុំអនុញ្ញាតចូលទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍។

ទទួលបានសារាចរនេះ សូមសាធារណជន ពលករ ពលការិនីមេត្តាជ្រាប និងអញ្ជើញទៅទំនាក់ទំនងជ្រើសរើសវិធីសាស្ត្រណាមួយតាមការគួរ។ល

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ទីភ្នាក់ងារជ្រើសរើសឯកជន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ